អន្តរប្វី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ កេរដំណែលដែលបុព្វបុរសខ្មែរបានបន្សល់ទុក ត្រូវកុលបុត្រកុលធីតាខ្មែររក្សាឲ្យគង់វង់ ។

website: www.hoksavann.org

ថ្ងៃទី១២ មីនា ២០០៨



បុព្វបុរសខ្មែរបានបន្សល់ទុកនូវកេរដំណែលជាច្រើន ឲ្យកុលបុត្រកុលធីតាខ្មែរ ប៉ុន្តែកេរដំណែលខ្លះបានត្រូវបាត់បង់ដោយសារកង្វះការថែរក្សាដោយការប្រុងប្រយ័ត្ន ។ កេរដំណែលទាំងនោះ មានជាអាទិ៍គឺទឹកដី ។ ដូនតាខ្មែរបានកាន់កាប់ទឹកដីមួយកន្លែង គឺប្រទេសកម្ពុជា ជាទឹកដីមានជីជាតិ មានធាតុអាកាសល្មម មិនក្តៅពេកមិនត្រជាក់ពេក ។ ជាទឹកន្លែងដ៏ល្អពុំដែលមានគ្រោះធម្មជាតិ ដូចជារញ្ជួយផែនដី ភ្លើងភ្នំផ្ទុះជាដើម ។ សម័យមហានគរចាប់ពីសតវត្សទី៩ដល់ទី១៣ ប្រទេសកម្ពុជាជាមហាអំណាចនៅអាស៊ីអាគ្នេយ៍ មានទឹកដីធំទូលំទូលាយ មានអារិយធម៌ដ៏រុងរឿង ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង ។ បច្ចុប្បន្ននេះ ទឹកដីដែលបុព្វបុរសខ្មែរបានប្រគល់ឲ្យកូនចៅខ្មែរ បានរួមតូច ហើយកំពុងតែបាត់បង់តទៅទៀត ដោយប្រទេសជិតខាងរំលោភយក ដោយសារតែខ្មែរខ្លួនឯងបាក់បែកសាមគ្គីគ្នា ។ កេរដំណែលធម្មជាតិមួយទៀត គឺព្រៃឈើដែលគ្របដណ្តប់ពាសពេញប្រទេសកម្ពុជា ចំនួនជាង៧០ភាគរយបានត្រូវកាប់បំផ្លាញ ។ ការពុំបានថែរក្សាកេរដំណែលនេះឲ្យគង់វង់ដូចដើម បណ្តាលឲ្យមានទឹកជំនន់និងភ្លៀងពុំបានធ្លាក់តាមប្រក្រតី ។ ដូនតាខ្មែរបានជ្រើសរើស ឲ្យខ្មែរគោរពព្រះពុទ្ធសាសនាថេរវាទ ទុកជាមាគ៌ាសំរាប់ជីវិតប្រចាំថ្ងៃ ព្រោះព្រះពុទ្ធសាសនាថេរវាទ ជាមាគ៌ាមានសច្ចភាព ដែលបានចង្អុលបង្ហាញផ្លូវទៅកាន់សេចក្តីសុខចំរើន ក្នុងសង្គមនិងផ្លូវទៅកាន់ការរំលត់ទុក្ខ ។ ក្រៅពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ចាស់បូរាណខ្មែរបានតែងនិពន្ធជាច្បាប់ទូន្មានផ្សេងៗ សំរាប់ឲ្យកូនចៅខ្មែរប្រតិបត្តិតាម ដូចជាច្បាប់ប្រុសច្បាប់ស្រី ច្បាប់ក្រម ច្បាប់កេរ្តិ៍កាលជាដើម ដែលច្បាប់ទាំ

ងនោះច្រើនផ្អែកទៅលើមូលដ្ឋានព្រះពុទ្ធសាសនា ។ សម្បត្តិសិល្បៈវប្បធម៌របស់ខ្មែរដ៏មានតម្លៃជាច្រើនទៀត ដែលខ្មែរលើកយកមកសិក្សានិងអនុវត្តសព្វថ្ងៃនេះ ដូចជាអក្សរសិល្ប៍ សិល្បៈរបាំចម្រៀង ដូរ្យដន្ត្រី ល្ខោន ភាពយន្ត គំនូរ ចម្លាក់ សំណង់ ការសូនរូបជាដើម ។ ប្រពៃណីទំនៀមទំលាប់ផ្សេងៗ ដូចជាប្រពៃណីបុណ្យទាន ប្រពៃណីពេលកូនកើត ពេលរៀបអាពាហ៍ពិពាហ៍ ប្រពៃណីពេលស្លាប់ និងរបៀបគួរសមនឹងគ្នា ពេលជួបគ្នាជាដើម ។ កេរដំណែលដែលមានលក្ខណៈពិសេសមួយទៀត គឺភាសានិងអក្សរ ។ ខ្មែរមានឯកភាពខាងភាសានិយាយ គឺខ្មែរគ្រប់ខេត្តទាំងអស់ទូទាំងប្រទេស និយាយស្តាប់គ្នាបាន ដោយប្រើភាសាតែមួយ គឺភាសាខ្មែរ ។ បុព្វបុរសខ្មែរបានរៀបចំរចនាអក្សរសំរាប់សរសេរ ដែលមានរាងរៅនិងន័យរបស់ពាក្យ ព្រមទាំងសម្លេង ស្របទៅតាមភាសានិយាយជាលក្ខណៈពិសេសរបស់ខ្លួន ។

វប្បធម៌ខ្មែរមានតម្លៃដ៏ខ្ពង់ខ្ពស់ ដែលជាវប្បធម៌មានមូលដ្ឋានពីព្រះពុទ្ធសាសនា ដែលបង្រៀនមនុស្សឲ្យលះបង់អំពើអាក្រក់គ្រប់យ៉ាង សាងសេចក្តីល្អ ជុះខាត់ជំរះចិត្តឲ្យស្អាតបរិសុទ្ធ ព្រោះចិត្តអាក្រក់នាំឲ្យសាងអាក្រក់ ។ ដោយសារវប្បធម៌ល្អ ការយកមកអប់រំកូនចៅក៏បានល្អ ។ ទំនៀមទំលាប់ខ្មែរ ការអប់រំកូនចៅ ត្រូវស្ថិតនៅលើមនុស្សព្រុក្រុម គឺឪពុកម្តាយ គ្រូបង្រៀន និងព្រះសង្ឃនៃព្រះពុទ្ធសាសនា ។

ឪពុកម្តាយខ្មែរជាពុទ្ធសាសនិកជន ដូច្នេះការអប់រំកូនចៅ ក៏យកគោលគំនិតរបស់ព្រះពុទ្ធសាសនា មកបន្ស៊ល់ឲ្យកូនចៅអនុវត្តតាម ។ ដូចជាការគោរពចាស់ព្រឹទ្ធាចារ្យ គោរពអ្នកមានសីល ឲ្យស្រឡាញ់រាប់អានបងប្អូន ឲ្យគោរពសិទ្ធិអ្នកដទៃ ហាមកូនចៅមិនឲ្យធ្វើអំពើបាបជាដើម ។ ព្រះពុទ្ធសាសនាបានពោលថា មនុស្សក្នុងសង្គម ដែលមានអ្នកធំអ្នកតូច អ្នកមានអ្នកក្រ គ្រូនិងសិស្ស ឪពុកម្តាយនិងកូន ស្វាមីនិងភរិយាជាដើម ត្រូវមានធម៌រៀងៗខ្លួន ។ ធម៌ក្នុងទីនេះ សំដៅយកការគោរពសិទ្ធិគ្នាទៅវិញទៅមកតាមមុខងាររបស់ខ្លួន ដោយមិនបៀតបៀនគ្នា ទើបសង្គមគ្រួសារ និងសង្គមជាតិបានសុខចំរើន ។ ជំនាន់ដើម កូនចៅប្រុសជំទង់ខ្មែរភាគច្រើន ត្រូវម្តាយឪពុកឲ្យទៅនៅវត្ត ដើម្បីបានសិក្សារៀនសូត្រអក្សរសាស្ត្រជាតិ និងសុំព្រះសង្ឃឲ្យជួយអប់រំកូនរបស់ខ្លួនឲ្យមានចរិ-យាល្អ របួតឲ្យបួសជាសាមណេរជាភិក្ខុទៀតផង សម័យនេះក៏នៅមានខ្លះ ។ ចំណែកកូនស្រី ទោះបីមិនបានរស់នៅក្នុងវត្ត មិនបានបួសដូចកូនប្រុស ប៉ុន្តែបានអប់រំចរិយាធម៌ពីឪពុកម្តាយ និងពីសាលារៀនដែរ ។ ដោយសារការអប់រំល្អនេះហើយ បានជាកូនចៅខ្មែរជំនាន់ដើម មិនដែលខូចកាយនិងគ្នា គឺមិនដែលប្រព្រឹត្តកន្លងប្រពៃណីក្នុងផ្លូវកាមគុណអំពីភេទប្រុសភេទស្រីឡើយ ។ ដោយសារឥទ្ធិពលព្រះពុទ្ធសាសនា បានធ្វើឲ្យជនជាតិខ្មែរស្រឡាញ់រាប់អានស្មោះត្រង់នឹងគ្នា ជឿបុណ្យជឿបាប ស្គាល់គុណស្គាល់ទោសបានដិតជាប់ក្នុងចិត្តជាអត្តសញ្ញាណរបស់ខ្លួន ។ ជនជាតិតែជួយទុក្ខធុរៈគ្នាទៅវិញទៅមក

ដូចជួយគ្នាក្នុងពេលសង់ផ្ទះ រៀបអាពាហ៍ពិពាហ៍កូនចៅ ពេលមានមនុស្សស្លាប់ ពេលច្រូតស្រូវជាដើម ។ ពេលខ្លះ បើមានការទាស់ទែងខ្វែងគំនិតគ្នា ជនជាតិខ្មែរនាំគ្នាទៅវត្តឲ្យព្រះសង្ឃជួយកាត់សេចក្តី ។ ព្រះសង្ឃក៏ជួយសំរុះសំរួលតាមធម៌អាថ៌ សាមីខ្លួនក៏ជានានឹងគ្នាវិញទៅ ។ ដូចបានពោលមកហើយ កេរដំណែលទាំងនេះ ដែលបុព្វបុរសខ្មែរបានបន្សល់ទុក ត្រូវជនជាតិខ្មែរគ្រប់គ្នារក្សាការពារឲ្យបានគង់វង់ ។៚

❄ ❄

❄